**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅ
# នៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌

*

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៦ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌

# ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់បេសកកម្ម មុខងារ ភារកិច្ច និងការរៀបចំអគ្គលេខាធិការដ្ឋាន របស់ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

## ជំពូកទី ២
## បេសកកម្ម រចនាសម្ព័ន្ធ មុខងារ និងភារកិច្ច

**មាត្រា ២.-**

ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានបេសកកម្មផ្តួចផ្តើម ជំរុញ ដាក់ឱ្យដំណើរការ និងតាមដានការអនុវត្តនយោបាយ និងកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ស្របតាមទិសដៅរបស់ ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ជាពិសេសពង្រឹងប្រព័ន្ធតុលាការជាតិ ។

**មាត្រា ៣.-**

ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានអគ្គលេខាធិការដ្ឋាន ជាសេនាធិការ។

**មាត្រា ៤.-**

ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានមុខងារ និងភារកិច្ចដូចតទៅ ÷

១. ផ្តួចផ្តើម និងលើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ នូវគម្រោងផែនការ កម្មវិធី កម្មវិធីការងារ និងយុទ្ធសាស្ត្រ សម្រាប់ធ្វើឱ្យសម្រេចគោលដៅទាំងឡាយ នៃកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

២. អនុវត្តសេចក្តីណែនាំ ដែលទទួលបានពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ក្នុងការដាក់ឱ្យដំណើរការយុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

៣. ចេញសេចក្តីសម្រេច និងសេចក្តីណែនាំចាំបាច់ដល់គ្រប់ក្រសួង ស្ថាប័ន ក្នុងការដាក់ឱ្យដំណើរការកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ក្នុងព្រំដែនសមត្ថកិច្ចរបស់ខ្លួន ។

៤. សម្របសម្រួលបណ្តាសកម្មភាពរបស់ក្រសួងនានា ដែលទាក់ទងទៅនឹងកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

៥. តាមដានអនុវត្តកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ នៅតាមក្រសួងនានានិងរាយការណ៍ពីលទ្ធផលទទួលបាន ជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ។

៦. លើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ នូវវិធានការចាំបាច់ទាំងឡាយក្នុងការដាក់ឱ្យដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

៧. ទំនាក់ទំនង សម្របសម្រួល យកចិត្តទុកដាក់ ដល់ការកេណ្ឌធនធានផ្ទាល់របស់រដ្ឋ និងជំនួយអន្តរជាតិចាំបាច់ សម្រាប់យកមកប្រើប្រាស់ ក្នុងការដាក់ឱ្យដំណើរការ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

៨. ផ្តល់ជូនក្រសួង ស្ថាប័នរដ្ឋក្នុងព្រំដែនសមត្ថភាពរបស់ខ្លួន នូវបង្អែកបច្ចេកទេសដែលមានអត្ថប្រយោជន៍ ដល់ក្រសួងទាំងអស់នោះ ពាក់ព័ន្ធនឹងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

## មាត្រា ៥.-

ប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានភារកិច្ចដូចតទៅ ៖

- ទទួលខុសត្រូវរួម ក្នុងការដាក់ឱ្យអនុវត្តនយោបាយ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- កំណត់របៀបវារៈនៃការប្រជុំនានា របស់ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- ដឹកនាំការពិភាក្សា និងចេញសេចក្តីសម្រេចនានា
- លើកសំណើ របស់ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ជូនក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ឬរាជរដ្ឋាភិបាលនូវគម្រោងរយៈពេលខ្លី រយៈពេលមធ្យម និង រយៈពេលវែង ។

## មាត្រា ៦.-

ប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌មានសិទ្ធិ ៖

- លើកសំណើតែងតាំង តាមករណីចាំបាច់ នូវអ្នកជំនាញការជាតិ អន្តរជាតិ និងឯកសូរជន ឬមន្ត្រីជាន់ខ្ពស់ដែលមានជំនាញក្នុងវិស័យនីតិកម្ម រដ្ឋបាល សេដ្ឋកិច្ច សង្គមកិច្ច ឬអភិបាលកិច្ចជាទីប្រឹក្សា ដើម្បីសិក្សាវិភាគធ្វើទស្សនទាន ឬធ្វើផែនការកម្មលើវិស័យកំណែទម្រង់ប្រព័ន្ធយុត្តិធម៌

- អញ្ជើញសមាជិករាជរដ្ឋាភិបាល ឬឯកសូរជន ដែលមានគុណសម្បត្តិមកចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

- អាចចុះហត្ថលេខាទ្វេភាគី ឬពហុភាគីលើគ្រប់កិច្ចសន្យា ឬអត្ថបទគតិយុត្តដែលទាក់ទងទៅនឹងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌បាន

- គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

## ជំពូកទី ៣
## អគ្គលេខាធិការដ្ឋាន

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ត្រូវបានដឹកនាំ និងគ្រប់គ្រង ដោយអគ្គលេខាធិការមួយរូប ។ អគ្គលេខាធិការមានអគ្គលេខាធិការរង ៗ និងមន្ត្រីជំនួយការតាមការចាំបាច់ ។

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានអគ្គលេខាធិការរងម្នាក់ទទួលបន្ទុកការងារអចិន្ត្រៃយ៍ ។

អគ្គលេខាធិការរង ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់អគ្គលេខាធិការ ដោយមានមតិយល់ព្រមពីប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

**មាត្រា ៨.-**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានបេសកកម្មដាក់ឱ្យដំណើរការកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ តាមការណែនាំ និងការចង្អុលទិសរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។ ក្នុងបេសកកម្មនេះ អគ្គលេខាធិការ មានភារកិច្ចជាអាទិ៍ សិក្សា និងលើកសំណើដាក់ជូនក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ នូវគម្រោង កំណែទម្រង់ប្រព័ន្ធយុត្តិធម៌សម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ព្រមទាំងរៀបចំធ្វើរបាយការណ៍ ជូនក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ អំពីលទ្ធភាពនៃការអនុវត្តគម្រោងទាំងនោះ ។

ក្នុងតួនាទីនេះ អគ្គលេខាធិការដ្ឋានមានភារកិច្ចតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោងកំណែទម្រង់យុត្តិធម៌ ព្រមទាំងវាយតម្លៃលទ្ធផលដែលសម្រេចបាន ។

**មាត្រា ៩.-**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានត្រាផ្ទាល់របស់ខ្លួន ។

**មាត្រា ១០.-**

អគ្គលេខាធិការមានសិទ្ធិលើកសំណើជូន ប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីពិនិត្យ និងសម្រេចតែងតាំង ឬដកចេញពីតំណែង នូវមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

**មាត្រា ១១.-**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានរចនាសម្ព័ន្ធដូចតទៅ ៖

១. ផ្នែករដ្ឋបាល និងផ្គត់ផ្គង់

២. ផ្នែកច្បាប់

៣. ផ្នែកតុលាការ

៤. ផ្នែកទំនាក់ទំនងនិងសម្របសម្រួល

**មាត្រា ១២.- ផ្នែកច្បាប់**

ផ្នែកច្បាប់មានភារកិច្ចដូចតទៅ ÷

- តាមដានការអនុវត្តច្បាប់
- ជំរុញការធ្វើវិសោធនកម្ម និងការកសាងច្បាប់
- ចូលរួមផ្តល់មតិចំពោះសេចក្តីព្រាង និងសេចក្តីស្នើច្បាប់
- រាយការណ៍ និងលើកស្នើយោបល់ការងារខាងលើជូនអគ្គលេខាធិការ
- បំពេញរាល់ការងារដែលអគ្គលេខាធិការប្រគល់ឱ្យ ។

**មាត្រា ១៣.- ផ្នែកតុលាការ**

ផ្នែកតុលាការមានភារកិច្ចដូចតទៅ ÷

- រៀបចំផែនការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- រៀបចំកម្មវិធី ចូលរួមពិនិត្យតាមដានការអនុវត្តកម្មវិធីកំណែទម្រង់ប្រព័ន្ធតុលាការ
- លើកសំណើព្រមទាំងរាយការណ៍ជូនក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- បំពេញរាល់ការងារដែលអគ្គលេខាធិការប្រគល់ឱ្យ ។

**មាត្រា ១៤.-ផ្នែករដ្ឋបាល និងផ្គត់ផ្គង់**

ផ្នែករដ្ឋបាល និងផ្គត់ផ្គង់ មានមុខងារ និងភារកិច្ចដូចតទៅ ÷

- សម្របសម្រួលផ្នែករដ្ឋបាល នូវរាល់សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រង និងថែរក្សាឯកសាររដ្ឋបាលផ្សេងៗ របស់អគ្គលេខាធិការដ្ឋាន
- ធានាប្រសិទ្ធភាព និងសុវត្ថិភាពរដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន
- សរុប និងធ្វើរបាយការណ៍អំពីការងាររួម និងសកម្មភាពផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន
- ផ្តល់ការគាំទ្រផ្នែកភស្តុភារចាំបាច់ដល់អគ្គលេខាធិការដ្ឋាន
- លើក និងអនុវត្តគម្រោងថវិកាប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន
- ប្រមូលផ្តុំចំណូល និងចំណាយរបស់អគ្គលេខាធិការដ្ឋាន
- តាមដាន និងលើកការអនុវត្តថវិកានិងការគ្រប់គ្រងគណនី របស់អគ្គលេខាធិការដ្ឋាន
- ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយឱ្យបានសមស្រប
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- រៀបចំ និងសម្រួលកិច្ចប្រជុំ និងការពិភាក្សារបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- កសាង និងដាក់ជូន នូវរបាយការណ៍ចំណាយប្រចាំត្រីមាស
- រាយការណ៍ និងលើកសំណើយោបល់ពីការងារខាងលើជូនអគ្គលេខាធិការ
- រ៉ាប់រងសេវាឯបណ្ណសារ និងឯកសារ ។

**មាត្រា ១៥.- ផ្នែកទំនាក់ទំនង និងសម្របសម្រួល**

ផ្នែកទំនាក់ទំនងនិងសម្របសម្រួល មានមុខងារនិងភារកិច្ចដូចតទៅ ÷

- ប្រមូលទិន្នន័យ និងទំនាក់ទំនងជាមួយស្ថាប័ននានា ដែលមានការពាក់ព័ន្ធនឹងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- សម្របសម្រួលការអនុវត្តកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ជាមួយប្រទេសផ្តល់ជំនួយ
- កេណ្ឌធនធាននិងជំនួយជាតិ និងអន្តរជាតិសម្រាប់បម្រើការក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- បំពេញរាល់ការងារដែលអគ្គលេខាធិការ ប្រគល់ឱ្យ ។

**មាត្រា ១៦.-**

អគ្គលេខាធិការដ្ឋាន ប្រើប្រាស់បុគ្គលិកនៃមុខងារសាធារណៈ ឬអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាបាន ។ ល័ក្ខខ័ណ្ឌនៃលាការរបស់ភ្នាក់ងារជាប់កិច្ចសន្យា និងប្រាក់បំណាច់ពិសេសសម្រាប់បើកជូនភ្នាក់ងារនៃមុខងារសាធារណៈ ត្រូវកំណត់ដោយសេចក្តីសម្រេច របស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ តាមសំណើរបស់អគ្គលេខាធិការ ។

**មាត្រា ១៧.-**

សមាជិក និងបុគ្គលិកទាំងអស់របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ អាចទទួលបាននូវប្រាក់បំណាច់ផ្សេងៗ ដែលបានផ្ទាល់ពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិនានា។

## ជំពូកទី ៣

## ប្រភពធនធាន

**មាត្រា ១៨.-**

ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានខ្ទង់ថវិកា ដោយឡែកនៅក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ១៩.-**

ធនធាន និងថវិការបស់ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ត្រូវបានផ្គត់ផ្គង់ដោយ ÷

- វិភាគទាននៃថវិកាជាតិ
- ហិរញ្ញប្បទានបានមកពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ២០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*រាជធានីភ្នំពេញ,ថ្ងៃទី ១៥ វិច្ឆិកា ឆ្នាំ ២០០១*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

" ដើម្បីសុំចុះហត្ថលេខា "

ប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌

ឌិត មុន្ទី

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២១
- ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ឯកសារ-កាលប្បវត្តិ